# ប្រកាសលេខ

# ០៥២

# ការរៀបចំបង្គន់

# អនាម័យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ 052 សកបយ

ភ្នំពេញ ថ្ងៃទី 10 ខែ កុម្ភៈ ឆ្នាំ ២០០០

# ប្រកាស
# ស្តីពី
# ការរៀបចំបន្ទប់អនាម័យ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨-៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦៩៩-០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ៨៧ អនក្រ.បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## សំរេច

ប្រការ១.- និយោជក នៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុង មាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវរៀបចំឱ្យមាននៅក្នុងបរិវេណ សហគ្រាស គ្រឹះស្ថានរបស់ខ្លួន នូវបន្ទប់សំរាប់ឱ្យកម្មករនិយោជិតបានប្រើប្រាស់ ដោយសមរម្យនិងមានអនាម័យល្អ ។

ប្រការ២.- ចំនួនបង្គន់ត្រូវរៀបចំឱ្យមានសំរាប់ភេទប្រុស និងភេទស្រីដាច់ផ្សេងគ្នាទៅតាមចំនួនកម្មករនិយោជិត ដូចតារាងខាងក្រោមនេះ ៖

| ចំនួនកម្មករនិយោជិត (ប្រុសឬស្រី) | ចំនួនបង្គន់ |
|---|---|
| ១នាក់ - ១៥នាក់ | ១ |
| ១៦នាក់ - ៣៥នាក់ | ២ |
| ៣៦នាក់ - ៥៥នាក់ | ៣ |
| ៥៦នាក់ - ៨០នាក់ | ៤ |
| ៨១នាក់ - ១១០នាក់ | ៥ |
| ១១១នាក់-១៥០នាក់ | ៦ |
| ១៥១នាក់-១០០០នាក់ | ថែម១សំរាប់៥០នាក់ |
| លើសពី១០០០នាក់ | ថែម១សំរាប់៧០នាក់ |

ប្រការ៣.- ការសាងសង់ត្រូវធ្វើឱ្យបានដូចខាងក្រោមនេះ ៖

- កំរាលក្រោមនិងជញ្ជាំងមិនជ្រាបទឹក
- ទ្វារជិតនិងមានគន្លឹះសំរាប់ខ្ទាស់ពីក្នុង
- ជញ្ជាំងត្រូវលាបពិណភ្លឺ
- មានពន្លឺល្អ
- មានតាក តភ្ជាប់ពីកន្លែងធ្វើការទៅបង្គន់ដើម្បីការពារទឹកភ្លៀង ។ ក្នុងករណីមិនអាចធ្វើតាកបាន និយោជកត្រូវផ្តល់មធ្យោបាយផ្សេងទៀតដើម្បីការពារទឹកភ្លៀង ។

ប្រការ៤.- ត្រូវរៀបចំយ៉ាងណាឱ្យទឹកដែលបង្ហូរចេញពីបង្គន់ ស្របតាមក្បួនអនាម័យ ។

ប្រការ៥. - ចំពោះសហគ្រាស គ្រឹះស្ថានដែលមានប្រើកម្មករនិយោជិតជាស្ត្រីភេទចាប់ពីមួយរយនាក់ឡើងទៅ ត្រូវធ្វើបង្គន់ខ្ពស់ដែលអាចអង្គុយផ្ទាល់ពីលើបានបន្ថែមមួយសំរាប់ស្ត្រីហាសិបនាក់ ។

00030

ប្រការ៦.- ទឹកសំរាប់ប្រើប្រាស់នៅតាមបង្គន់ត្រូវឱ្យបានគ្រប់គ្រាន់ មានសភាពស្អាតនិងថ្លា ។ សាប៊ូក៏ត្រូវមានគ្រប់គ្រាន់នៅតាមបង្គន់និមួយៗ ។ បង្គន់ទាំងអស់ត្រូវបានទទួលការសំអាត ថែទាំ ដុសលាង យ៉ាងហោចបានម្តងក្នុងមួយថ្ងៃ ។

ប្រការ៧.- អ្នកប្រព្រឹត្តល្មើសនិងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ ។

ប្រការ៨.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ស្.

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូន :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ (ដើម្បីជូនជ្រាប)
- អគ្គនាយកដ្ឋាន ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (ដើម្បីផ្សព្វផ្សាយនិងអនុវត្ត)
- គ្រប់មន្ទីរសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង (ដើម្បីផ្សព្វផ្សាយនិងអនុវត្ត)
- សមាគមនិយោជក (ដើម្បីអនុវត្ត)
- សហភាពសហជីព (ដើម្បីអនុវត្ត)
- គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍ (ដើម្បីជួយផ្សព្វផ្សាយ)
- កាលប្បវត្តិ និងឯកសារ



37